**គណបក្សប្រជាជនកម្ពុជា**

គណៈកម្មាធិការកណ្តាល

**លេខ៖** 411/16 **សស.គក**

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ

អព្យាក្រឹត និងវឌ្ឍនភាពសង្គម

*រាជធានីភ្នំពេញ ថ្ងៃទី 19 ខែឧសភា ឆ្នាំ២០១៦*

# សេចក្តីសម្រេច

## ស្តីពី

## តួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំង និងរបៀបរបបធ្វើការ

## របស់គណៈចលនាយុវជន នៃគណៈចលនាមហាជន គណៈកម្មាធិការកណ្តាល

* * * * * * * * * * * * * * * * * *

**យោង ៖**

- សេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលលេខ ៣២៧/១៥ សស.គក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ ស្តីពីតួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការងាររបស់គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល
- សេចក្តីណែនាំបន្ថែម លេខ ០១/១៦ សណ.គក ចុះថ្ងៃទី២៥ ខែ មករា ឆ្នាំ ២០១៦ ស្តីពីការរៀបចំប្រធានគណៈចលនាមហាជន ប្រធានគណៈចលនាយុវជន នៃគណបក្សរាជធានី ខេត្ត
- ស្មារតីអង្គប្រជុំរបស់គណៈប្រចាំការ នៃគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាល នាថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៦

## គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលសម្រេច

**ប្រការ១**: - គណៈចលនាយុវជន អក្សរកាត់ "គ.ច.យ" មានតួនាទីជាសេនាធិការរបស់គណៈចលនាមហាជន របស់គណបក្ស ក្នុងការប្រមូលផ្តុំអង្គការយុវជន ទាំងក្នុង និងក្រៅគណបក្ស ដែលមាននិន្នាការស្របនឹងគណបក្ស លើមូលដ្ឋានទស្សនៈទាននយោបាយ សង្គម និងមនោគមន៍វិជ្ជា ដើម្បីកសាងជួរយុវជនជាពលរដ្ឋ ដែលមានសមត្ថភាព សកម្ម និងមានការទទួលខុសត្រូវក្នុងសង្គម និងកសាងកម្លាំងគាំទ្រដ៏មានសក្តានុពលក្នុងការគាំទ្រគណបក្សប្រជាជនកម្ពុជា។

- គណៈចលនាយុវជន ដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តភារកិច្ចរបស់អង្គការចាត់តាំងយុវជន យន្តការ និងក្រុមការងារទាំងអស់របស់គណបក្ស ដែលបំពេញការងារចលនាយុវជន ដើម្បីធានាបាននូវសុខដុមនីយកម្ម និងជោគជ័យលើការងារចលនាយុវជន ក្រោមការដឹកនាំរបស់គណបក្ស។

**ប្រការ២**: គណៈចលនាយុវជន មានតួនាទីក្នុងការៈ

១. ដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ភារកិច្ចរបស់អង្គការចាត់តាំងយុវជនផ្សេងៗ ដែលមាននិន្នាការស្របនឹងបក្សក្នុងការកសាង និងការគ្រប់គ្រងកម្លាំងយុវជន។

២. បង្កើននូវប្រសិទ្ធភាពនៃការដឹកនាំរបស់អង្គការចាត់តាំងយុវជនផ្សេងៗ ដែលមាននិន្នាការស្របនឹងបក្ស ដើម្បីធានាបាននូវប្រៀបខ្លាំង និងប្រៀបឈ្នះរបស់អង្គការចាត់តាំងយុវជននីមួយៗ ក្នុងការកសាង និងការគ្រប់គ្រងកម្លាំងយុវជនទាំងបរិមាណ និងគុណភាព នៅគ្រប់កាលៈទេសៈ ។

**ប្រការ៣**: គណៈចលនាយុវជន មានភារកិច្ចៈ

ដើម្បីបំពេញតួនាទីខាងលើ គណៈចលនាយុវជនមានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

១. ផ្តួចផ្តើមគំនិត និងផ្តល់យោបល់ ជូនគណៈចលនាមហាជន ដើម្បីកំណត់សម្រេចគោលនយោបាយ និងគោលការណ៍នានាសំដៅប្រមូលកម្លាំងគាំទ្រគណបក្ស ។

២. កំណត់ដែនប្រតិបត្តិ និងការទទួលខុសត្រូវឱ្យច្បាស់លាស់ទៅតាមស្ថានភាពជាក់ស្តែង ព្រមទាំងមានការសម្របសម្រួល ដើម្បីអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

៣. អនុវត្តផែនការសកម្មភាពយុវជនស្របតាមគោលការណ៍ «វិមជ្ឈការ» ដោយសហការជាមួយក្រុមការងារថ្នាក់ខេត្ត។ កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រ ១២ ចំណុច ក្នុងការអភិវឌ្ឍយុវជនដូចខាងក្រោមៈ

១- អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ ដើម្បីគាំទ្រការអនុវត្តគោលនយោបាយ និងផែនការនានាឲ្យមានប្រសិទ្ធភាព។
២- លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព។
៣- បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព។
៤- បណ្តុះស្មារតីសហគ្រិនភាព និងការយល់ដឹងអំពីទីផ្សារការងារ។
៥- លើកកម្ពស់កិច្ចការពារសុវត្ថិភាព សន្តិសុខ និងយុត្តិធម៌។
៦- បង្កើនការចូលរួមរបស់យុវជន។
៧- លើកកម្ពស់ការសម្រាក ការកម្សាន្ត និងកីឡា។
៨- លើកកម្ពស់សិល្បៈ និងវប្បធម៌។
៩- លើកកម្ពស់ការយល់ដឹងពីបរិស្ថាន កសិកម្ម និងទេសចរណ៍។
១០-បង្កើនការងារស្ម័គ្រចិត្ត។
១១-លើកកម្ពស់សមភាពយេនឌ័រ។
១២-ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងស្តារយុវនីតិសម្បទា។

៤. គ្រប់គ្រង និងពង្រឹងកម្លាំងដែលមានក្នុងដៃឱ្យបានច្បាស់លាស់តាមអង្គភាពនីមួយៗ ។

៥. តាមដាន ឈ្វេងយល់ពីស្ថានភាពសង្គម និងយុវជន ដើម្បីមានវិធានការណ៍ឆ្លើយតបជាក់ស្តែងឱ្យបានសមស្រប និងទាន់ពេលវេលាតាមគ្រប់រូបភាព ។

៦. សហការជាមួយគ្រប់អង្គការចាត់តាំងបក្ស ស្ថាប័ននានាគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ អន្តរជាតិ និងសប្បុរសជន ដើម្បីប្រមូលផ្តុំធនធាន និងការគាំទ្រ ដោយមានការស្នើសុំគោលការណ៍ពីបក្ស ។

៧. ធ្វើរបាយការណ៍ និងបូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនគណៈចលនាមហាជន ។

៨. បំពេញភារកិច្ចផ្សេងៗដែលគណៈចលនាមហាជនប្រគល់ជូន។

**ប្រការ៤**: គណៈចលនាយុវជនមានរចនាសម្ព័ន្ធដូចខាងក្រោម៖

គណៈចលនាយុវជន មាន ២ ថ្នាក់ គឺ៖

- **ថ្នាក់កណ្តាល** ហៅថាគណៈចលនាយុវជន ដែលមានប្រធាន អនុប្រធាន សមាជិក និងមានលេខាធិការដ្ឋាន ដែលមានប្រធាន ០១ រូប អនុប្រធាន ០២ រូប និងសមាជិកមួយចំនួនតាមការចាំបាច់
- **ថ្នាក់រាជធានី ខេត្ត** ហៅថាគណៈចលនាយុវជន នៃគណបក្សរាជធានី ខេត្ត ដែលមានអភិបាលរាជធានី ខេត្ត ជាប្រធាន និងមានអនុប្រធាន សមាជិក តាមការចាំបាច់។ ចំពោះថ្នាក់ក្រុង ស្រុក ខណ្ឌ អភិបាលក្រុង ស្រុក ខណ្ឌទទួលបន្ទុកផ្ទាល់ការងារចលនាយុវជន។

**ប្រការ៥**: របៀបរបបធ្វើការ របស់គណៈចលនាយុវជន

- គណៈចលនាយុវជន ធ្វើការតាមរបបសមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ ដូច្នេះ រាល់ការសម្រេចត្រូវគោរពតាមមតិភាគច្រើនដាច់ខាត រីឯរបបប្រជុំត្រូវធ្វើប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ឬតាមការចាំបាច់។
- ប្រធាន និងអនុប្រធាន បំពេញភារកិច្ចប្រចាំការ ដើម្បីដោះស្រាយការងារប្រចាំថ្ងៃ តាមការប្រគល់សិទ្ធិពីគណៈចលនាមហាជន។

  លេខាធិការដ្ឋាន មានតួនាទីទទួលខុសត្រូវលើការរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនអគ្គលេខាធិការដ្ឋាន នៃគណៈចលនាមហាជន និងធ្វើទំនាក់ទំនងជាមួយក្រុមយុវជននានា។

**ប្រការ៦**: ខុទ្ទកាល័យ គណៈចាត់តាំង គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ និងគណៈចលនាយុវជន ត្រូវប្រតិបត្តិតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ជ.គណៈអចិន្ត្រៃយ៍
អនុប្រធាន

**សាយ ឈុំ**

**ចម្លងជូន៖**

-សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល

-ដូចប្រការ ៦

-ឯកសារ-កាលប្បវត្តិ